# មនុស្សម្នាក់ក្នុងចំណោមបណ្ដាជន

អែលឌើរ ដានីស ប៊ី នែនស្វាន់ឌើរ
នៃក្រុម 70 នាក់

*ចូរយើងឆ្ពោះទៅមុខដោយស្ងៀមស្ងាត់ និងទាំងស្រុងទៅកាន់ព្រះអង្គសង្គ្រោះ ដោយមានសេចក្ដីជំនឿថា ទ្រង់យកចិត្តទុកដាក់អំពីយើង និងមានព្រះចេស្ដាដើម្បីព្យាបាល និងសង្គ្រោះយើង ។*

នៅក្នុងគម្ពីរលូកា យើងបានអានអំពីស្ត្រីម្នាក់ ដែលមានជម្ងឺធ្លាក់ឈាមយ៉ាងរ៉ាំរ៉ៃអស់រយៈពេល 12 ឆ្នាំ។ គាត់បានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដើម្បីរកថ្នាំព្យាបាល ប៉ុន្តែរកមិនបានសោះ។ នៅក្នុងចំណោមបណ្ដាជនយ៉ាងច្រើន ស្ត្រីម្នាក់នេះបានទៅរកព្រះអង្គសង្គ្រោះពីក្រោយ ហើយបានពាល់ជាយសំលៀកបំពាក់របស់ទ្រង់។ ព្រះយេស៊ូវចង់ជ្រាបថាតើនរណាបានពាល់ទ្រង់ ពីព្រោះទ្រង់មានអារម្មណ៍ថា ព្រះចេស្ដាបានចេញពីទ្រង់ទៅ។ ពួកសាវកមិនយល់ពីសំណួរនោះ ហើយបានសួរថាៈ "លោកគ្រូ បណ្ដាជនកំពុងប្រជ្រៀតគ្នាតឿតទ្រង់ ដូច្នេះទ្រង់មានបន្ទូលថា អ្នកណាពាល់ទ្រង់ធ្វើអ្វី?" 1 បន្ទាប់មកស្ត្រីម្នាក់នេះ ដោយមានសេចក្ដីភ័យខ្លាចយ៉ាងខ្លាំង និងញាប់ញ័របានសារភាពថា គឺជារូបគាត់ដែលបានទៅពាល់ទ្រង់ ហើយបានត្រូវជាសះស្បើយភ្លាម។ ព្រះអង្គសង្គ្រោះបានបញ្ជាគាត់ឱ្យទៅដោយសុខសាន្ត ទាំងទូលដល់គាត់ថា សេចក្ដីជំនឿរបស់នាងបានសង្គ្រោះនាងហើយ ។

មានអ្វីៗជាច្រើនដើម្បីរៀនសូត្រ និងពិចារណានៅក្នុងដំណើររឿងដ៏ខ្លីគួរឱ្យចាប់អារម្មណ៍នេះ។

ខ្ញុំអាចស្រមៃឃើញពីបណ្ដាជនទាំងនោះ។ បណ្ដាជនទាំងនោះច្បាស់ជាកុះករ នៅពេលដែលមនុស្សរុញប្រច្រៀតគ្នាប៉ះព្រះយេស៊ូវ។ ច្បាស់ជាមានសម្លេងបណ្ដាជនអ៊ូរអរ នៅពេលមនុស្សរុញច្រានគ្នា ព្យាយាមដើម្បីមើលទ្រង់ឱ្យច្បាស់។ ខ្ញុំឆ្ងល់ថាហេតុអ្វីក៏ពួកគេនៅទីនោះ។ ភាគច្រើន ខ្ញុំគិតថាបណ្ដាជនមកដោយសារការចង់ដឹងចង់ឮ។ នៅកន្លែងណាដែលទ្រង់យាងទៅ នោះព័ត៌មានអំពីការយាងមករបស់ទ្រង់ និងដំណើររឿងនៃអព្ភូតហេតុទាំងឡាយបានត្រូវសុះសាយជាមុន។ ប្រហែលជាពួកគេរំពឹងទុកថានឹងបានឃើញរឿងអ្វីមួយប្លែកពីធម្មតា ជាព្រឹត្តិការណ៍ដែលមិនគួររំលងឡើយ។ ទោះជាមិនបានប្រាប់ក្ដី មានពួកផារិស៊ីនៅក្នុងបណ្ដាជន ដែលពួកគេតែងតែព្យាយាមរកឱកាសដើម្បី ដាក់អន្ទាក់ធ្វើឲ្យមានភាពអាម៉ាស ឬស្វែងរកអ្វីមួយដែលពួកគេអាចផ្ដន្ទាទោសព្រះយេស៊ូវ។ តើវាអាចទៅរួចទេដែលមនុស្សមួយចំនួននៅក្នុងចំណោមបណ្ដាជននោះមកដើម្បីសើចចំអក?

នៅក្នុងចំណោមបណ្ដាជនគឺមានស្ត្រីម្នាក់។ ខ្ញុំឃើញស្ត្រីរាបសា ប្រហែលជាមានការខ្មាស់អៀនច្រើន បានព្យាយាមទៅពីក្រោយព្រះអង្គសង្គ្រោះ ហើយបន្ទាប់មកដោយសេចក្ដីខ្មាស់អៀន បានសារភាពថា នាងបានពាល់ជាយសំលៀកបំពាក់របស់ទ្រង់។ គាត់គឺជាស្ត្រីដែលមានការនឿយហត់ និងក្រីក្រដោយក្ដីលំបាករបស់នាង។ គាត់បាក់ទឹកចិត្ត។ រូបរាងខាងក្រៅ គាត់បង្ហាញឱ្យឃើញនូវភាពខុសគ្នា ពីមនុស្សជាច្រើនទៀតដែលនៅក្នុងចំណោមបណ្ដាជន។ គ្មាននរណាម្នាក់ព្យាយាមបញ្ឈប់គាត់ពីការប្រជ្រៀត ទៅមុខរកព្រះយេស៊ូវទេ។ ជាជាក់ស្ដែង ពួកសាវកថែមទាំងមិនបានឃើញនាង ឬព្យាយាមបញ្ឈប់នាងឡើយ។ ប៉ុន្តែមានអ្វីមួយដែលធ្វើឱ្យនាងមានការខុសប្លែកពីពួកមនុស្សដទៃនៅក្នុងបណ្ដាជនទាំងអស់នៅថ្ងៃនោះ។ ទោះបីជាកប់នៅក្នុងចំណោមបណ្ដាជន គាត់ព្យាយាមខំទៅមុខដោយអង់អាច

និងស្ងប់ស្ងាត់ជាមួយនឹងគំនិតតែមួយគត់ នៅក្នុងគំនិតថាៈ មករកព្រះអង្គសង្គ្រោះ ដោយមានសេចក្តីជំនឿថា ទ្រង់មានព្រះចេស្តាដើម្បីព្យាបាលនាង ថាទ្រង់ខ្វាល់ខ្វាយពីនាង ហើយអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់នាង។ នៅក្នុងកិច្ចការតែមួយនេះ នាងបានធ្វើឱ្យខ្លួនរបស់នាងប្លែកពីបណ្តាជន។ បណ្តាជនមកដើម្បីមើល ប៉ុន្តែស្ត្រីម្នាក់នេះមកដើម្បីព្យាបាល។

មានដំណើររឿងដែលគួរឱ្យចាប់អារម្មណ៍ដទៃទៀត នៅក្នុងព្រះគម្ពីរនៃមនុស្សដ៏ស្មោះត្រង់ម្នាក់ ក្នុងចំណោមបណ្តាជន។ អាលម៉ា បាននៅក្នុងចំណោមពួកសង្ឃទុច្ចរិតនៃស្តេចណូអេ។ បុរសទាំងនេះគឺត្រូវបានពិពណ៌នាថាត្រូវលើកឡើងនៅក្នុងអំនួតនៃបេះដូងរបស់ពួកគេខ្ជិលច្រអូស និងគោរពរូបសំណាក់ ជាអ្នកដែលនិយាយកុហក់ និងពាក្យអត់ប្រយោជន៍ដល់ប្រជាជន។ 2 ពួកគេបានធ្វើឱ្យខូចដល់ផ្លូវនៃព្រះអម្ចាស់ ពីព្រោះពួកគេមិនបានអនុវត្តន៍បេះដូងរបស់ពួកគេដើម្បីឱ្យមានការយល់ដឹងនោះទេ។ 3 នៅពេលអ័ប៊ីណាដៃ បានផ្សាយពីសារលិខិតនៃការប្រែចិត្ត ពួកគេបានសើចចំអកគាត់ ហើយនៅទីបញ្ចប់បានសម្លាប់គាត់។ នេះគឺជាបណ្តាជនដែលទុច្ចរិតដោយពិត។ ប៉ុន្តែ ដូចដែលព្រះគម្ពីរលើកឡើងថាៈ "មានមនុស្សម្នាក់នៅក្នុងចំណោមពួកនោះ" 4 ដែលបានជឿ។ គឺអាលម៉ាតែម្នាក់ឯងគត់ដែលស្តាប់តាមនូវអ្វីដែលអ័ប៊ីណាដៃបានបង្រៀន។ ជាមួយនឹងសេចក្តីក្លាហាន គាត់បានបោះជំហានចេញពីបណ្តាជន ដើម្បីធ្វើតាមព្រះអម្ចាស់។ ឥទ្ធិពលនៃបុរសម្នាក់នេះនៅក្នុងចំណោមបណ្តាជន នៅក្នុងដំណើរនៃរឿងសាសន៍នីហ្វៃគឺមិនអាចកាត់ថ្លៃបាន។

បណ្តាជនដែលត្រូវបានស្គាល់យ៉ាងច្បាស់មួយនៅក្នុងព្រះគម្ពីរមរមន គឺបណ្តាជនដែលនៅអគារដ៏ធំ ហើយទូលាយ នៅក្នុងការនិមិត្តរបស់ លីហៃអំពីដើមជីវិត។ អគារនោះគឺពេញទៅដោយមនុស្ស ទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី ដែលពួកគេកំពុងចំអកឡកឡឺយ ហើយចង្អុលដៃខ្លួនទៅរកពួកអ្នកដែលកំពុងតែទទួលទានផ្លែឈើពីដើមនោះ។ 5 នៅទីបំផុត ពួកអ្នកខ្លះបានភ្លក់ផ្លែឈើបានស្តាប់តាមបណ្តាជន ហើយ "បានធ្លាក់តាមផ្លូវហាមឃាត់ទាំងឡាយ ហើយវង្វេងបាត់អស់ទៅ។" 6 ទោះជាយ៉ាងនោះក្តីក៏មានមនុស្សផ្សេងទៀតដែលជាអ្នកបានទទួលទានផ្លែឈើ ហើយមិនបានស្តាប់តាមបណ្តាជន។7 បណ្តាជនទាំងនេះគឺជាអ្នកដែលបានរីករាយ ជាមួយនឹងពរជ័យនៃដើមជីវិត។

នៅក្នុងជីវិតពិត រឿងទាំងនេះគឺមិនមែនអំពីបណ្តាជននោះទេ ប៉ុន្តែអំពីបុគ្គលម្នាក់ៗដែលនៅក្នុងចំណោមបណ្តាជន។ រឿងទាំងនេះគឺអំពីអ្នក និងខ្ញុំ។ យើងទាំងអស់គ្នានៅក្នុងចំណោមបណ្តាជន នៃពិភពលោកនេះ។ យើងទាំងអស់គ្នាស្ទើរតែដូចជាស្ត្រីដែលផ្ទុយពីបណ្តាជនដែលទៅរកព្រះអង្គសង្គ្រោះ។ យើងទាំងអស់គ្នាមានសេចក្តីជំនឿដែលគ្រាន់តែពាល់ម្តងប៉ុណ្ណោះ នឹងធ្វើឱ្យព្រលឹងដែលឈឺរបស់យើងបានព្យាបាល ហើយសម្រាលពីសេចក្តីត្រូវការដ៏ច្រើនបំផុតរបស់យើង។ 8 សមាជិកថ្មីទាំងឡាយនៃសាសនាចក្រ នៅលើទឹកដីជាច្រើន ជាញឹកញាប់គឺដូចជាអាលម៉ា។ ពួកគេបានស្តាប់ឮព្រះបន្ទូលនៃជីវិត នៅពេលដែលគ្មាននរណាផ្សេងនៅក្នុងផ្ទះរបស់ពួកគេ ឬមិត្តភក្តិរបស់ពួកគេបានស្តាប់ឮនោះ។ ប៉ុន្តែពួកគេនៅតែមានសេចក្តីក្លាហាន ដើម្បីទទួលយកដំណឹងល្អ និងរៀបចំផ្លូវរបស់ពួកគេផ្ទាល់ប្រជ្រៀតនឹងបណ្តាជន។ ខ្ញុំគិតថាយើងម្នាក់ៗយល់អំពីអត្ថន័យនៃការទទួលទានផ្លែឈើនៃដើមជីវិតឱ្យបានពេញលេញ ទាំងការមើលឃើញ និងសម្លេងនៃពួកអ្នកដែលចំអកឡកឡឺយ និងអត្ថន័យក្នុងការអនុវត្តន៍សេចក្តីក្លាហានខិតខំ ដើម្បីកុំយកចិត្តទុកដាក់ស្តាប់ដល់ពួកចំអក។

ការពុះពារនៅក្នុងចំណោមបណ្ដាជន នៃពិភពលោកអាចធ្វើឱ្យឯកកោ និងលំបាក។ ឥទ្ធិពល និងការទទួលរង របស់ពួកគេលើបុគ្គលម្នាក់ៗដែលមានចិត្តចង់បោះជំហានចេញ ដើម្បីធ្វើអ្វីមួយដែលប្រសើរជាង នោះអាចជារឿងដ៏រឹងមាំ និងពិបាកដើម្បីយកឈ្នះ។

តើនរណាអាចឈោងទៅជួយទៅឧបត្ថម្ភ ហើយនៅទីបំផុតសង្គ្រោះមនុស្សម្នាក់ដែលនៅក្នុងចំណោមបណ្ដាជនឱ្យប្រសើរជាងព្រះអង្គសង្គ្រោះនោះ? ទ្រង់ជ្រាបដឹងនូវអ្វីទៅជាការព្យាយាម នៅក្នុងចំណោមបណ្ដាជន ដែលគ្មានការកោតខ្លាច ហើយនៅតែបន្តនៅពិត។ បណ្ដាជនខាងលោកិយមិនស្គាល់ទ្រង់ទេ បាននិយាយថា: "ទ្រង់ឥតមានទ្រង់ទ្រាយល្អ ឬសណ្ឋានល្អទេ" ហើយថា "គ្មានភាពលំអរណាដែលឱ្យយើងរីករាយចិត្តដែរ" 9 ស្ដេចបេនយ៉ាមីន បានមានបន្ទូលថាពិភពលោក "ចាត់ទុកថាព្រះអង្គជាមនុស្សម្នាក់"។ 10 អេសាយបានពិពណ៌នាថែមទៀត ពីកន្លែងរបស់ព្រះគ្រីស្ទ នៅក្នុងចំណោមបណ្ដាជន នៃពិភពលោកនូវពាក្យទាំងនេះថា:

ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្ដីឈឺចាប់:...ទ្រង់ត្រូវគេមើលងាយ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ។ ទ្រង់បានទ្រាំទ្ររងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងជាពិត។11

នីហ្វៃបានសរសេរថា: "ហើយមនុស្សលោក ដោយព្រោះសេចក្ដីទុច្ចរិតរបស់ពួកគេ នោះនឹងចាត់ទុកទ្រង់ជាគ្មានតម្លៃទៅវិញ"។12

ប៉ុន្តែនៅទីបំផុត ព្រះរាជបុត្រាច្បងរបស់ព្រះ ដែលជាញឹកញាប់ ត្រូវបានគេវិនិច្ឆ័យខុស និងមិនយល់អំពីទ្រង់នឹងងើបចេញពីចំណោមបណ្ដាជនដូចជាអ្នក "ដែលបានចាក់ប្រេងតាំង" ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះ នៃពិភពលោក។ ការលេចឡើងនេះគឺត្រូវបានទស្សទាយយ៉ាងរាបទាប នៅក្នុងសេចក្ដីថ្លែងការណ៍ របស់ព្រះអង្គសង្គ្រោះដល់ពួកមេសង្ឃមួយចំនួន និងពួកអែលឌើរដែល "ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញនោះ បានត្រឡប់ជាថ្មជ្រុងយ៉ាងឯក"។13

បងប្អូនប្រុសស្រីជាទីស្រឡាញ់ ខ្ញុំសូមអធិស្ឋានថា យើងម្នាក់ៗអាចឆ្លងកាត់ដោយសុវត្ថិភាព នូវបណ្ដាជននៃពិភពលោក។ នៅក្នុងស្ថានភាពរបស់ជីវិតទាំងអស់ សូមឱ្យយើងស្ងប់ស្ងាត់ និងអង់អាចបោះជំហានឆ្ពោះទៅមុខរកព្រះអង្គសង្គ្រោះ ដោយមានជំនឿថា ទ្រង់ខ្វល់ខ្វាយអំពីយើង ហើយមានព្រះចេស្ដា ដើម្បីព្យាបាល និងសង្គ្រោះយើង។ សូមឱ្យយើងស្ដាប់ព្រះបន្ទូលនៃជីវិតរបស់ទ្រង់ ហើយចូលរួមយ៉ាងពេញទំហឹង ជាបន្តបន្ទាប់ និងដោយសេចក្ដីក្លាហានចំពោះផលផ្លែដែលមកពីព្រះបន្ទូលរបស់ទ្រង់។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. លូកា 8:45។
2. សូមមើលម៉ូសាយ 11:5--11។
3. សូមមើលម៉ូសាយ 12:25--27។
4. ម៉ូសាយ 17:2។
5. សូមមើលនីហ្វៃទី 1 8:27។
6. នីហ្វៃទី 1 8:28។

7. សូមមើលនីហ្វៃទី 1 8:33 ។

8. សូមមើលលូកា 4:18 ។

9. អេសាយ 53:2 ។

10. ម៉ូសាយ 3:9 ។

11. ម៉ូសាយ 53:3--4 ។

12. នីហ្វៃទី 1 19:9 ។

13. ម៉ាថាយ 21:42 ។